សៀមរាប ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ សម្រាប់ថវិកាថ្នាក់ក្រោមជាតិព្រមទាំងការចុះអង្កេតផ្ទៀងផ្ទាត់សហគ្រាស និងការធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យក្នុងខេត្តសៀមរាប នៅសាលាខេត្តសៀមរាប ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ២និង០០នាទីរសៀល ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ រួមជាមួយ ឯកឧត្តម **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាល ខេត្តសៀមរាប ក្នុងនាមជាសហប្រធាន បានដឹកនាំកិច្ចប្រជុំស្តីអំពី "ការពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ សម្រាប់ថវិកាថ្នាក់ក្រោមជាតិ ព្រមទាំងការចុះអង្កេតផ្ទៀងផ្ទាត់សហគ្រាស និងការធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យក្នុងខេត្តសៀមរាប" ដែលបានរៀបចំឡើងនៅសាលាខេត្តសៀមរាប ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយករង ព្រមទាំងឯកឧត្តម-លោក អភិបាលរង លោក លោកស្រី ជាមន្ត្រីជំនាញនៃសាខាពន្ធដារខេត្តសៀមរាប និងមន្ត្រីពាក់ព័ន្ធមកពីស្ថាប័ន-មន្ទីរនានាជុំវិញខេត្ត។

កិច្ចប្រជុំថ្ងៃនេះ មានគោលដៅសំខាន់ក្នុងការពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ សម្រាប់ថវិកាថ្នាក់ក្រោមជាតិ ក្នុងនោះមានពន្ធអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធប្រថាប់ត្រាជាដើម ដែលជាថវិកាថ្នាក់ក្រោមជាតិ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៤-២០១៨ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ជាមួយគ្នានេះ កិច្ចប្រជុំបានផ្តោតលើ ការចុះអង្កេតផ្ទៀងផ្ទាត់សហគ្រាសក្នុងខេត្តសៀមរាប និងការធ្វើបច្ចុប្បន្នភាពទិន្នន័យអចលនទ្រព្យ។ ដើម្បីអនុវត្តការងារនេះ ឱ្យបានជោគជ័យ អគ្គនាយកដ្ឋានពន្ធដារ ចាំបាច់សុំកិច្ចសហការពី ឯកឧត្តមអភិបាលខេត្តសៀមរាប និងអាជ្ញាធរមូលដ្ឋានជុំវិញខេត្ត។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម គង់ វិបុល បានបញ្ជាក់ថា អគ្គនាយកដ្ឋានពន្ធដារ ក៏តែងតែយកចិត្តទុកដាក់ខ្ពស់ ក្នុងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៤-២០១៨ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ គឺមិនមានការបង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធ គឺមានតែពង្រឹងការគ្រប់គ្រងប្រមូលពន្ធ។ លើសពីនេះទៀត រាជរដ្ឋាភិបាលតែងតែគិតគូរដល់ប្រជាពលរដ្ឋ អ្នករកស៊ីតូចតាច តាមរយៈការលុបចោលនូវរបបម៉ៅការ ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រប់ ឆ្នាំ២០១៦ ដែលក្នុងនោះប្រជាពលរដ្ឋជាអាជីវករតូចតាច បែបលក្ខណៈគ្រួសារ ដូចរៀបរាប់ខាងលើ ហើយមានកម្រិតផលរបរក្រោម ២៥០លានរៀល គឺជាកម្មវត្ថុនៃការលើកលែងពន្ធ និងមិនមានកាតព្វកិច្ចសារពើ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ពន្ធទេ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តសម្រាប់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម តាមរយៈអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម និងប្រកាសលេខ ៥០២សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ